# ចូលក្នុងវិញ្ញាណរបស់អ្នក

ថ្នាក់ទី 1 - សិល្បៈភាសាអង់គ្លេស លំអានអក្សរសិល្ប៍ 1.4

| ស្តង់ដារមុខវិជ្ជាគោល | ជាមូលដ្ឋាន នេះមានន័យថាកូនរបស់អ្នកអាច.... |
|---|---|
| RL.1.4 លំអានអក្សរសិល្ប៍ 1.4 កំណត់ពាក្យ និងឃ្លានៅក្នុងរឿង ឬកំណាព្យដែលលើកឡើងអំពីអារម្មណ៍ ឬពាក់ព័ន្ធ នឹងវិញ្ញាណ។ | ប្រើប្រាស់វិញ្ញាណ និងអារម្មណ៍របស់ពួកគេឲ្យមានទំនាក់ទំនងជាមួយនឹងអត្ថបទ |

## ព័ត៌មានគោលៈ

មានពេលខ្លះដែលអ្នកនិពន្ធប្រើប្រាស់ពាក្យ ឬឃ្លាដើម្បីឲ្យទាញការចូលរួមរបស់កូនរបស់លោកអ្នកតាមរយៈអារម្មណ៍ ឬវិញ្ញាណ។ កូនរបស់អ្នកអាចនឹងជួបពាក្យមួយចំនួន ដែលត្រូវបានប្រើប្រាស់ដើម្បីភ្ជាប់ទៅនិងវិញ្ញាណរបស់ពួកគេ។ ឧទាហរណ៍ "កណ្តឹងបានរោទិ៍យ៉ាងខ្លាំងជាសញ្ញាប្រកាសប្រាប់សិស្សក្នុងសាលាថា មានការហ្វឹកហាត់អគ្គីភ័យ។" ឧទាហរណ៍នេះគឺពាក់ព័ន្ធទៅនឹងវិញ្ញាណ។ ឧទាហរណ៍ មួយទៀត "ជូលី (Julia) យំអស់រយៈពេលមួយម៉ោង ពីព្រោះនាងបានបាត់ខ្សែកដែលជីដូនរបស់នាងឲ្យនាងក្នុងថ្ងៃបុណ្យណូអែល"។ ឧទាហរណ៍នេះគឺពាក់ព័ន្ធនឹងអារម្មណ៍។ ខណៈពេលដែលកូនរបស់អ្នក ឬអ្នកកំពុងអាន កូនរបស់អ្នកគួរស្វែងរកពាក្យ ឬឃ្លាដែលទាក់ទងនឹងវិញ្ញាណ និងអារម្មណ៍។

## សកម្មភាពៈ

1. ចាប់ផ្តើមនិយាយទៅកាន់កូនរបស់អ្នកអំពីពាក្យទាក់ទងនឹងអារម្មណ៍។ អ្នកអាចប្រើប្រាស់ផ្ទាំងរូបភាពដែលទាក់ទងនឹងអារម្មណ៍ដើម្បីជាជំនួយដល់ការពិភាក្សារបស់អ្នក (ផ្នែកធនធានឯកសារ)។
2. តម្រូវឲ្យកូនរបស់អ្នកធ្វើកាយវិការតាមអារម្មណ៍និមួយៗ ដែលមានលើផ្ទាំងរូបភាព។ (ឧទាហរណ៍ សម្រាប់អារម្មណ៍ "ភ័យ" ពួកគេអាចខិនលាក់មុខ ដូចជាកំពុងពួន ជាដើម។)
3. ខណៈពេលដែលអ្នក ឬកូនរបស់អ្នកកំពុងអាន អ្នកត្រូវស្វែងរកចំណុចទាំងឡាយដែលតួអង្គបង្ហាញពីអារម្មណ៍។
4. នៅពេលដែលតួអង្គបង្ហាញអារម្មណ៍ កូនរបស់អ្នកអាចចង្អុលទៅកាន់អារម្មណ៍ដែលតួអង្គបង្ហាញក៏បាន ឬសម្តែងចេញអារម្មណ៍ក៏បាន។ ឧទាហរណ៍ "កុមារីតូច Little Red Riding Hood បានដើរយឺតៗនៅក្នុងព្រៃដោយឱនក្បាលចុះក្រោម។"កូនរបស់អ្នកអាចចង្អុលទៅកាន់រូបភាពនៅក្នុងតារាង ឬធ្វើទឹកមុខដែលបង្ហាញពីការកើតទុក្ខ។

## សកម្មភាពៈ

1. សកម្មភាពបន្ទាប់នឹងតម្រូវឲ្យកូនរបស់អ្នកចំណាំពីវិញ្ញាណរបស់ពួកគេ។
2. និយាយទៅកាន់កូនរបស់អ្នកអំពីវិញ្ញាណរបស់ពួកគេ (សោតវិញ្ញាណ កាយវិញ្ញាណ ជីវ្ហាវិញ្ញាណ ឃានវិញ្ញាណ និងចក្ខុវិញ្ញាណ)។
3. ខណៈពេលដែលអ្នក ឬកូនរបស់អ្នកកំពុងអានរឿង ចូរស្វែងរកពាក្យ ឬឃ្លាដែលទាក់ទងនឹងវិញ្ញាណ (សោតវិញ្ញាណ កាយវិញ្ញាណ ជីវ្ហាវិញ្ញាណ ឃានវិញ្ញាណ និងចក្ខុវិញ្ញាណ)។
4. គ្រប់ពេលដែលកូនរបស់អ្នកឮពាក្យ ឬឃ្លាដែលទាក់ទងនឹងវិញ្ញាណរបស់ពួកគេ ពួកគេនឹងត្រូវប៉ះផ្នែករាងកាយនោះ។ ឧទាហរណ៍ "ក្មេងប្រុសតូចនោះបានដើរទៅក្នុងផ្ទះបាយ ចានបានធ្លាក់ទៅលើកម្រាលឥដ្ឋដោយមានសម្លេង **ប្រាវ**!" កូនរបស់អ្នកនឹងចង្អុលទៅកាន់ត្រចៀករបស់គេ។

## ធានធានឯកសារ៖




## សម្ភារដែលអ្នកត្រូវការ៖

- សៀវភៅ
- ផ្ទាំងរូបភាពបង្ហាញពីអារម្មណ៍

www.childtherapytoys.com